# សម័យប្រជុំល្ងាចថ្ងៃសៅរ៍

ថ្ងៃទី 5 ខែ មេសា ឆ្នាំ 2008

## ផ្នែករបាយការណ៍ការធ្វើសវនកម្មសាសនាចក្រឆ្នាំ 2007

ធ្វើឧទេស្មនាមដោយ រ៉បប៊ឺត ដបបិលយូ ខេនវេល
នាយករៀបចំផ្នែកធ្វើសវនកម្មសាសនាចក្រ

*ជូនចំពោះគណៈប្រធានទីមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*

បងប្អូនប្រុសជាទីស្រលាញ់ៈ ដូចដែលបានសរសេរដោយវិវរណៈ នៅក្នុងកណ្ឌទី 120 នៃគោលលទ្ធិ និងសេចក្តីសញ្ញា ក្រុមប្រឹក្សាបែងចែកដង្វាយមួយភាគក្នុងដប់ អនុញ្ញាតក្នុងការចំណាយមូលនិធិរបស់សាសនាចក្រ ។ ក្រុមប្រឹក្សានេះ ត្រូវបានរៀបចំឡើងដោយគណៈប្រធានទីមួយ ក្រុមនៃពួកសាវកដប់ពីរនាក់ និងគណៈប៊ីស្សពជាអធិបតី ។ ក្រុមប្រឹក្សានេះអនុមតិថវិកាសំរាប់ការិយាល័យផ្នែក និងការប្រតិបត្តិការទាំងឡាយនៃសាសនាចក្រ ។ ក្រុមប្រឹក្សានេះ អនុមតិនូវថវិកាសំរាប់ផ្នែក និងការប្រតិបត្តិការទាំងឡាយនៃសាសនាចក្រ ។ បន្ទាប់ពីទទួលការ អនុញ្ញាតពីក្រុមប្រឹក្សានេះ នោះផ្នែកទាំងឡាយនៃសាសនាចក្រគឺអាចចំណាយមូលនិធិទាំងឡាយ នៅក្នុងរង្វង់ថវិកាដែលបានអនុមតិឱ្យខ្ជាប់ខ្ជួន ហើយឱ្យស្របទៅតាមគោលការណ៍ និងទម្រង់ការទាំងឡាយរបស់សាសនាចក្រ ។

ផ្នែកសវនកម្មសាសនាចក្រ ត្រូវបានអនុញ្ញាតឱ្យចូលទៅគ្រប់កំណត់ហេតុ និងប្រពន្ធ័ដែលចាំបាច់ទាំងអស់ ដើម្បីវាយតំលៃសមត្ថភាពគ្រប់គ្រងលើវិក័យប័ត្រមូលនិធិ ការចំណាយ និងការការពារធនធានសាសនាចក្រ ។ ការិយាល័យ ផ្នែកសវនកម្មសាសនាចក្រ គឺជាការិយាល័យឯករាជ្យពីការិយាល័យផ្នែក និងការប្រតិបត្តិការទាំងឡាយរបស់សាសនាចក្រ ព្រមទាំងបុគ្គលិកដែលមានបញ្ជាក់ជាគណនេយ្យករសាធារណៈ ជាសវនករខាងក្នុងអង្គភាពដែលមានការបញ្ជាក់ ជាសវនករលើប្រពន្ធ័ពត៌មានដែលមានការបញ្ជាក់ និងអ្នកជំនាញការទទួល បានសារតាំងដទៃៗទៀត ។

ផ្អែកទៅលើសវនកម្មដែលបានធ្វើរួចហើយ ការិយាល័យផ្នែកសវនកម្មសាសនាចក្រមានទស្សនៈថា រាល់ឯកសារទាំងអស់ត្រូវបានបង្កប់ បានទទួលការចែកចាយ បានធ្វើការចំណាយ ហើយធនធានសាសនាចក្រសំរាប់ឆ្នាំ 2007 ត្រូវបានកត់ត្រាទុក និងគ្រប់គ្រងតាមការអនុវត្តគណនេយ្យត្រឹមត្រូវ ថវិការទាំងឡាយបានមានការអនុមតិ និងស្របតាមគោលការណ៍ និងទម្រង់ការទាំងឡាយរបស់សាសនាចក្រ ។

សូមដាក់ជូនដោយការគោរពដ៏ជ្រាលជ្រៅ

ផ្នែកសវនកម្មសាសនាចក្រ
រ៉បប៊ឺត ដបបិលយូ ខេនវេល
នាយកចាត់ចែង